**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រសួងព័ត៌មាន
MINISTRY OF INFORMATION

**ក្រសួងព័ត៌មាន**

លេខ ០៨៥ ប្រ.ក ពម

# ប្រកាស
## ស្តីពី
## ការដាក់ឲ្យអនុវត្តធម្មនុញ្ញវិជ្ជាជីវៈសារព័ត៌មាន

## រដ្ឋមន្ត្រីក្រសួងព័ត៌មាន

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៤ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងព័ត៌មាន
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨៩៥/០៧ ចុះថ្ងៃទី០១ ខែកញ្ញា ឆ្នាំ១៩៩៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីរបបសារព័ត៌មាន
- បានឃើញអនុក្រឹត្យលេខ៧០ អនក្រ.បក ចុះថ្ងៃទី០៥ ខែសីហា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងព័ត៌មាន
- បានឃើញអនុក្រឹត្យលេខ៧១ អនក្រ.បក ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០០៧ ស្តីពីការកែសម្រួលអគ្គនាយកដ្ឋាន រដ្ឋបាលនិងសោតទស្សន៍ ជាអគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ និងអគ្គនាយកដ្ឋានព័ត៌មាននិងសោតទស្សន៍
- យោងតាមសំណូមពរ និងភាពចាំបាច់នៃការងារអនុវត្តវិជ្ជាជីវៈសារព័ត៌មាន។

## សម្រេច

**ប្រការ១.-**

ត្រូវបានដាក់ឲ្យអនុវត្តធម្មនុញ្ញវិជ្ជាជីវៈសារព័ត៌មានដូចមានភ្ជាប់ក្នុងឧបសម្ព័ន្ធនៃប្រកាសនេះ។



អគារលេខ ៦២ មហាវិថីព្រះមុនីវង្ស សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ
Building62, Monivong BLVD,Sangkat Srah Chork, Khan Daun Penh, PhnomPenh E-mail:information@info.gov.kh

**ប្រការ២.-**

ប្រកាសនេះ មានវិសាលភាពអនុវត្តចំពោះអ្នកអនុវត្តសកម្មភាពក្នុងវិស័យព័ត៌មាន និងសោតទស្សន៍ទាំងអស់នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

ធម្មនុញ្ញវិជ្ជាជីវៈសារព័ត៌មាននេះ ជាមូលដ្ឋានគ្រឹះនៃក្រមសីលធម៌វិជ្ជាជីវៈសារព័ត៌មានកម្ពុជា។

**ប្រការ៣.-**

គណៈកម្មការវាយតម្លៃ និងលើកសរសើរការអនុវត្តធម្មនុញ្ញវិជ្ជាជីវៈសារព័ត៌មាននេះ ត្រូវបង្កើតឡើងដោយលិខិតបទដ្ឋានគតិយុត្តដោយឡែក។

**ប្រការ៤.-**

ខុទ្ទកាល័យ គ្រប់អគ្គនាយកដ្ឋាននិងអង្គភាពក្រោមឱវាទក្រសួងព័ត៌មាន និងអ្នកអនុវត្តសកម្មភាពនៅក្នុងវិស័យព័ត៌មាននិងសោតទស្សន៍ទាំងអស់នៅក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តតាមប្រកាសនេះឱ្យមានប្រសិទ្ធភាពខ្ពស់ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ អង្គារ ២ កើត ខែ ស្រាពណ៍ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៦ ខែ សីហា ឆ្នាំ២០២៤

**រដ្ឋមន្ត្រី**

**នេត្រ ភក្ត្រា**

**កន្លែងទទួល៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ខុទ្ទកាល័យ **សម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី**
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- រដ្ឋបាលរាជធានី ខេត្ត

  «ដើម្បីជូនជ្រាប»
- ដូចប្រការ៤

«ដើម្បីអនុវត្ត»
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# ធម្មនុញ្ញវិជ្ជាជីវៈសារព័ត៌មាន

ខែសីហា ឆ្នាំ២០២៤

# ជំពូកទី១
## គោលបំណង វិសាលភាព និងនិយមន័យ

**១**.- ធម្មនុញ្ញវិជ្ជាជីវៈសារព័ត៌មាននេះ មានគោលបំណងបន្តជានាបរិយាកាសល្អប្រសើរសម្រាប់ការអនុវត្តក្រមសីលធម៌វិជ្ជាជីវៈសារព័ត៌មានប្រកបដោយទំនុកចិត្ត ប្រសិទ្ធភាព គុណភាព និងទំនួលខុសត្រូវវិជ្ជាជីវៈ ជាផ្នែកសម្រាប់ការលើកកម្ពស់សេរីភាពខាងសារព័ត៌មាន និងការពារសុវត្ថិភាពអ្នកសារព័ត៌មាន។ ធម្មនុញ្ញនេះកំណត់ទិដ្ឋភាពសំខាន់ៗដូចខាងក្រោមៈ

ក) កំណត់និយាមអប្បបរមាសម្រាប់សកម្មភាពផ្សព្វផ្សាយព័ត៌មានគ្រប់ទម្រង់ និងតាមគ្រប់មធ្យោបាយ ក្នុងគោលបំណងធានាសង្គតិភាពនៃការប្រតិបត្តិក្រមសីលធម៌វិជ្ជាជីវៈសារព័ត៌មានរួមនៅទូទាំងព្រះរាជាណាចក្រកម្ពុជា សំដៅធានា *«ភាពពិត ត្រឹមត្រូវ ស្មោះត្រង់ យុត្តិធម៌ មិនលម្អៀង និងគោរពសិទ្ធិអ្នកដទៃ»* ក្នុងការផ្សព្វផ្សាយព័ត៌មាន។

ខ) បណ្ដុះនិងបញ្ជ្រាបផ្នត់គំនិតនៃការផ្សារភ្ជាប់សេរីភាពខាងសារព័ត៌មាន ជាមួយកាតព្វកិច្ច និងទំនួលខុសត្រូវក្នុងក្របខណ្ឌច្បាប់ដើម្បីរក្សាបាននូវគុណតម្លៃនិងឥទ្ធិពលជាវិជ្ជមាននៃវិជ្ជាជីវៈសារព័ត៌មានក្នុងសង្គមកម្ពុជា។

គ) តម្រង់ទិសលើការប្រតិបត្តិក្រមសីលធម៌ក្នុងវិស័យព័ត៌មាននិងសោតទស្សន៍ ដើម្បីធានាសន្តិសុខព័ត៌មាននៅព្រះរាជាណាចក្រកម្ពុជា និងបញ្ជ្រាបការយល់ដឹងអំពីភាពចាំបាច់នៃការអនុវត្តប្រកបដោយសុខដុមនីយកម្មក្នុងចំណោមតួអង្គពាក់ព័ន្ធទាំងអស់ នូវគោលការណ៍គ្រឹះនៃវិជ្ជាជីវៈសារព័ត៌មាន ខណៈគ្រប់តួអង្គត្រូវសម្របខ្លួនទៅតាមការវិវឌ្ឍរីកចម្រើននៃបច្ចេកវិទ្យា និងបញ្ញាសប្បនិម្មិត (AI) ដើម្បីធានានូវលំហសេរីភាពខាងសារព័ត៌មានប្រកបដោយគុណភាព សុវត្ថិភាព និងបរិយាប័ន្ន។

ឃ) លើកកម្ពស់ការផ្សព្វផ្សាយព័ត៌មានពិត ត្រឹមត្រូវ គ្រប់ជ្រុងជ្រោយ ប្រកបដោយតុល្យភាព និងមានប្រភពច្បាស់លាស់ ព្រមទាំងចូលរួមបង្ការ ទប់ស្កាត់ និងប្រឆាំងដំណឹងក្លែងក្លាយ ព័ត៌មានក្លែងបន្លំ ព័ត៌មានបំភ្លៃ និងព័ត៌មានភាន់ច្រឡំ ព័ត៌មានដែលមានលក្ខណៈខុសពីការពិត ដើម្បីធានាភាពជឿជាក់ និងទុកចិត្តក្នុងសង្គមជាតិទាំងមូល សំដៅលើកកម្ពស់វិស័យសារព័ត៌មាន តាមគន្លងមាគ៌ានៃលទ្ធិប្រជាធិបតេយ្យ និងនីតិរដ្ឋក្នុងការរួមចំណែកធានាបាននូវសន្តិសុខព័ត៌មាន ការពារ និងថែរក្សាសុខសន្តិភាព និងការអភិវឌ្ឍប្រកបដោយចីរភាពនៅកម្ពុជា។

**២**.- ធម្មនុញ្ញវិជ្ជាជីវៈសារព័ត៌មាននេះ មានវិសាលភាពអនុវត្តចំពោះ«អ្នកអនុវត្តសកម្មភាពក្នុងវិស័យព័ត៌មាន និងសោតទស្សន៍» ទាំងអស់នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**២.១**- ធម្មនុញ្ញនេះជានិយាមប្រតិបត្តិក្រមសីលធម៌វិជ្ជាជីវៈសម្រាប់អ្នកប្រកបអាជីពសារព័ត៌មានគ្រប់ជំនាញ ដែលមានជាអាទិ៍អ្នកសារព័ត៌មានអាជីព អ្នកសារព័ត៌មានរូបថត អ្នកសារព័ត៌មានអនឡាញ អ្នកសារ

ព័ត៌មានគ្មានអង្គភាព អ្នកសារព័ត៌មានវិទ្យុនិងទូរទស្សន៍ អ្នកបោះពុម្ពផ្សាយ អង្គភាពសារព័ត៌មាន សមាគមអ្នកសារព័ត៌មាន ព្រមទាំងអ្នកប្រកបអាជីពនិងសកម្មភាពវិជ្ជាជីវៈផ្សេងទៀត ទាំងនៅក្នុងប្រព័ន្ធផ្សព្វផ្សាយប្រពៃណី និងប្រព័ន្ធផ្សព្វផ្សាយបែបថ្មី។

**២.២-** ធម្មនុញ្ញនេះក៏ជាវិធានសម្រាប់តម្រង់ទិសលើក្រមសីលធម៌ និងការទទួលខុសត្រូវសង្គមរបស់អ្នកផ្សព្វផ្សាយព័ត៌មានដែលមិនមែនជាអ្នកសារព័ត៌មានអាជីព ដែលរួមមានជាអាទិ៍ អ្នកបង្កើតមាតិកាលើបណ្ដាញទំនាក់ទំនងសង្គមនិងបណ្ដាញអនឡាញគ្រប់ប្រភេទ អ្នកសរសេរប្លុក អ្នកសារព័ត៌មានពលរដ្ឋ (ឬពលរដ្ឋសារព័ត៌មាន) អ្នកកេប្រាក់តាមប្រព័ន្ធអនឡាញគ្រប់ទម្រង់ និងអ្នកមានប្រជាប្រិយភាព (Key Opinion Leader ឬ KOL)។

**៣.-** វាក្យស័ព្ទសំខាន់ៗ ដែលប្រើនៅក្នុងធម្មនុញ្ញវិជ្ជាជីវៈសារព័ត៌មានកម្ពុជានេះ ត្រូវបានកំណត់និយមន័យដូចខាងក្រោម៖

១) **ធម្មនុញ្ញវិជ្ជាជីវៈសារព័ត៌មាននេះ** សំដៅដល់មូលដ្ឋានគោលការណ៍គ្រឹះរួមនៃក្រមសីលធម៌វិជ្ជាជីវៈសារព័ត៌មាន។

២) **ព័ត៌មាន** សំដៅដល់ហេតុការណ៍ ព្រឹត្តិការណ៍ ឬដំណឹងដែលគេផ្ដល់ឱ្យសាធារណជនដឹងតាមរយៈប្រព័ន្ធផ្សព្វផ្សាយជាអក្សរ សំឡេង រូបភាព សញ្ញា ឬក្រោមទម្រង់ផ្សេងទៀតដែលមានប្រភពច្បាស់លាស់ និងត្រូវបានផ្ទៀងផ្ទាត់ត្រឹមត្រូវ។

៣) **សារព័ត៌មាន** សំដៅដល់បណ្ដាញផ្សព្វផ្សាយព័ត៌មានឬដំណឹងជាសាធារណៈ ទាំងប្រព័ន្ធផ្សព្វផ្សាយប្រពៃណីនិងប្រព័ន្ធផ្សព្វផ្សាយបែបថ្មីគ្រប់ប្រភេទ។

៤) **អ្នកសារព័ត៌មាន** សំដៅដល់អ្នកដែលប្រកបអាជីព វិជ្ជាជីវៈជាចម្បង និងជាប្រចាំផ្នែកសារព័ត៌មាន។

៥) **អ្នកសារព័ត៌មានពលរដ្ឋ (ឬពលរដ្ឋសារព័ត៌មាន)** សំដៅដល់ប្រជាពលរដ្ឋ និងសាធារណជនទូទៅដែលប្រមូល ចែកផ្សាយ វិភាគព័ត៌មាន ឬដំណឹងចម្រុះ ជាពិសេសតាមរយៈអ៊ីនធឺណិតនិងបណ្ដាញទំនាក់ទំនងសង្គម។

៦) **អ្នកសារព័ត៌មានគ្មានអង្គភាព** សំដៅដល់អ្នកសារព័ត៌មានដែលធ្វើការដោយឯករាជ្យផ្ទាល់ខ្លួន ដោយមិនចំណុះឬបម្រើឱ្យអង្គភាពណាមួយ។ អ្នកសារព័ត៌មានប្រភេទនេះចែកចាយ ឬលក់អត្ថបទ និងរូបភាពឱ្យប្រព័ន្ធផ្សព្វផ្សាយដទៃ។

៧) **អ្នកសារព័ត៌មានរូបថត** សំដៅដល់អ្នកសារព័ត៌មានដែលប្រើការថតរូបជាមធ្យោបាយដើម្បីផលិតរាយការណ៍ និងផ្សព្វផ្សាយព័ត៌មាន។

៨) **អ្នកសារព័ត៌មានអាជីព** សំដៅដល់អ្នកសារព័ត៌មានដែលទទួលបានការអប់រំ បណ្ដុះបណ្ដាល ឬបំពាក់បំប៉នវិជ្ជាជីវៈសារព័ត៌មាន ហើយបំពេញការងារទៅតាមក្រមសីលធម៌វិជ្ជាជីវៈ ដើម្បីទទួលបានប្រាក់កម្រៃ។

៩) **អង្គភាពសារព័ត៌មាន** សំដៅដល់ក្រុមបុគ្គល ឬនីតិបុគ្គល ដែលផ្សព្វផ្សាយព័ត៌មានជាសាធារណៈតាមប្រព័ន្ធផ្សព្វផ្សាយប្រពៃណី និង/ឬទំនើប។

១០) **សារព័ត៌មានអេឡិចត្រូនិក** (Electronic Media) សំដៅដល់ប្រព័ន្ធផ្សព្វផ្សាយតាមប្រព័ន្ធអេឡិចត្រូនិក (អស្សាណ្ឌ) ដូចជា ស្ថានីយ៍វិទ្យុ ទូរទស្សន៍ ទូរទស្សន៍ខ្សែកាប ដែលផ្សាយតាមផ្កាយរណប អ៊ីនធឺណិត ទូរសារ (Fax) CD-ROM ។ល។ ក៏ជាសារព័ត៌មានអេឡិចត្រូនិកដែរ។

១១) **អ្នកផលិតមាតិកា** សំដៅដល់បុគ្គលដែលបង្កើតនិងគ្រប់គ្រងមាតិកាជាវីដេអូ រូបភាព អត្ថបទ ។ល។ សម្រាប់ការផ្សាយតាមប្រព័ន្ធអ៊ីនធឺណិត លើថ្នាលឌីជីថលគ្រប់ទម្រង់ ជាពិសេសបណ្ដាញទំនាក់ទំនងសង្គម។

១២) **អ្នកមានប្រជាប្រិយភាព** (Key Opinion Leader ឬ KOL) សំដៅដល់បុគ្គលដែលត្រូវបានទទួលស្គាល់ជាអ្នកជំនាញលើប្រធានបទណាមួយ ដែលមានសមត្ថភាព ឬឥទ្ធិពលអាចបំផុសគំនិតសាធារណៈអំពីបញ្ហា ផលិតផល ឬសេវាកម្ម។ ពួកគេអាចជាតារាសិល្បៈ អ្នកនិពន្ធ វាគ្មិន ឬអ្នកមានឥទ្ធិពលសង្គម។

១៣) **ប្លុក** (Blog) សំដៅដល់វេបសាយ ដែលបុគ្គលណាម្នាក់ ឬក្រុមណាមួយ បញ្ចូលព័ត៌មានផ្សេងៗ ឬព័ត៌មានទាក់ទងនឹងប្រធានបទណាមួយសម្រាប់ការចែកចាយជាសាធារណៈ។

១៤) **បញ្ញាសិប្បនិម្មិត(AI)** សំដៅដល់ផ្នែកមួយនៃវិទ្យាសាស្ត្រកុំព្យូទ័រផ្ដោតលើការបង្កើតកម្មវិធី ឬឧបករណ៍កុំព្យូទ័រដែលមានសមត្ថភាពអាចធ្វើការសម្រេចចិត្តដោយខ្លួនឯងបាន ឬធ្វើសកម្មភាពជំនួសមនុស្ស។

១៥) **សន្តិសុខព័ត៌មាន**សំដៅដល់ការធានាការទទួលព័ត៌មានប្រកបដោយគុណភាព និងសុវត្ថិភាព។

១៦) **ប្រព័ន្ធផ្សព្វផ្សាយប្រពៃណី** (Traditional Media) សំដៅដល់ប្រព័ន្ធផ្សព្វផ្សាយដែលកើតមុនសម័យអ៊ីនធឺណិត ដូចជា កាសែត ទស្សនាវដ្ដី សៀវភៅអាន វិទ្យុ ទូរទស្សន៍ និងភាពយន្ត។

១៧) **ប្រព័ន្ធផ្សព្វផ្សាយបែបថ្មី** (New Media) សំដៅដល់ប្រព័ន្ធផ្សព្វផ្សាយបែបថ្មីក្នុងសតវត្សរ៍ទី២១ ដែលកំណត់អ្វីៗទាក់ទងនឹងអ៊ីនធឺណិតដោយមានអន្តរកម្មរវាងអ្នកផ្សព្វផ្សាយ និងអ្នកប្រើប្រាស់ ឬអ្នកប្រើប្រាស់ និងអ្នកប្រើប្រាស់នូវបច្ចេកវិទ្យាថ្មី ទាំងរូបភាព និងសំឡេង។ និយមន័យរបស់ពាក្យនេះប្រែប្រួលឥតឈប់ឈរ តាមការវិវត្តវិទ្យាសាស្ត្រ និងបច្ចេកវិទ្យាព័ត៌មានទាំងអាណាឡូក (Analogue) និងឌីជីថល (Digital) ដូចជា Facebook YouTube បណ្ដាញទំនាក់ទំនងសង្គម...។ល។

១៨) **សមាគមអ្នកសារព័ត៌មាន** សំដៅដល់ការចងក្រងជាក្រុមរវាងអ្នកសារព័ត៌មានច្រើននាក់ ឬអង្គភាពសារព័ត៌មានផ្សេងៗ នៅក្នុង កម្រិតជាតិ និងអន្តរជាតិ ដើម្បីជួយការពារផលប្រយោជន៍អ្នកសារព័ត៌មាន។

១៩) **បណ្ដាញទំនាក់ទំនងសង្គម** សំដៅដល់មធ្យោបាយទំនើបប្រើប្រាស់សម្រាប់ភ្ជាប់ទំនាក់ទំនងចែករំលែកព័ត៌មាន សម្ដែងមតិ ដើរដោយប្រព័ន្ធអ៊ីនធឺណិត លើទូរស័ព្ទចល័ត កុំព្យូទ័រ ឬឧបករណ៍អេឡិចត្រូនិកផ្សេងទៀត ដែលអាចបញ្ជូនសំឡេង អក្សរ រូបភាព វីដេអូ។

២០) **ដំណឹងក្លែងក្លាយ** (Fake News) សំដៅដល់សាច់រឿងមិនពិតដែលត្រូវបានគេប្រឌិត ឬកែច្នៃជាព័ត៌មានក្នុងទម្រង់ជាអត្ថបទ រូបភាព វីដេអូ សំឡេង ... ហើយយកទៅផ្សព្វផ្សាយលើប្រព័ន្ធអ៊ីនធឺណិត ឬបណ្តាញសារព័ត៌មានផ្សេងៗ ក្នុងបំណងកេងចំណេញនយោបាយ អាជីវកម្ម និង/ឬធ្វើឱ្យជ្រួលច្របល់ក្នុងសង្គម។

២១) **ព័ត៌មានក្លែងបន្លំ** (Disinformation) សំដៅដល់ប្រភេទព័ត៌មានមិនពិតដែលបានបង្កើតឡើង ហើយយកទៅផ្សព្វផ្សាយ ឬចែកចាយ ដោយចេតនាដើម្បីបំភាន់ ឬបោកប្រាស់សាធារណជន ក្នុងគោលបំណងបង្កផលប៉ះពាល់ដល់ជនណាម្នាក់ អង្គការណាមួយ ឬប្រទេសណាមួយ។

២២) **ព័ត៌មានបំភ្លៃ** (Malinformation) សំដៅដល់ប្រភេទព័ត៌មានមិនពិតដែលត្រូវបានគេកែច្នៃពីព័ត៌មានពិត ហើយត្រូវបានគេយកមកផ្សព្វផ្សាយឬចែកចាយក្នុងចេតនាធ្វើឱ្យប៉ះពាល់ផលប្រយោជន៍ កិត្តិយសបុគ្គល អង្គការ ស្ថាប័ន ឬប្រទេសណាមួយ។

២៣) **ព័ត៌មានភាន់ច្រឡំ** (Misinformation) សំដៅដល់ប្រភេទព័ត៌មានមិនពិតដែលត្រូវបានគេផ្សព្វផ្សាយ ឬចែករំលែកតៗគ្នាដោយចេតនាឬអចេតនាធ្វើឱ្យមានការយល់ច្រឡំ ហើយជួនកាលអ្នកចែករំលែកមិនដឹងច្បាស់ពីប្រភពនៃព័ត៌មានដែលខ្លួនទទួលបានដោយគ្មានបំណងធ្វើឱ្យខូចខាត ឬប៉ះពាល់ផលប្រយោជន៍បុគ្គល ស្ថាប័ន ឬប្រទេសណាមួយឡើយ។

២៤) **អ្នកបោះពុម្ពផ្សាយ** សំដៅដល់បុគ្គលដែលធ្វើសកម្មភាពបោះពុម្ពផ្សាយព័ត៌មាន សម្រាប់ការចែកចាយជាសាធារណៈ ដែលរួមមានជាអាទិ៍ ការបោះពុម្ពផ្សាយ កាសែត ទស្សនាវដ្តី សៀវភៅ ខិត្តប័ណ្ណ អាហ្វីស ប៉ាណូ ផ្ទាំងផ្សព្វផ្សាយ ប័ណ្ណផ្សាយពាណិជ្ជកម្ម ស្លាកផលិតផល ជាដើម។

២៥) **រោងពុម្ព** សំដៅដល់ក្រុមហ៊ុន ឬអង្គភាពដែលសកម្មភាពអាជីវកម្មពាក់ព័ន្ធនឹងការផលិតបោះពុម្ព។

## ជំពូកទី២
## គោលការណ៍គ្រឹះជាមូលដ្ឋាននៃវិជ្ជាជីវៈសារព័ត៌មាន និងការផ្សព្វផ្សាយព័ត៌មាន

### ផ្នែកទី១
### សេរីភាពផ្សារភ្ជាប់នឹងទំនួលខុសត្រូវ

៤.- ការអនុវត្តសេរីភាពខាងសារព័ត៌មាន និងសេរីភាពខាងការបោះពុម្ពផ្សាយមិនត្រូវប្រាសចាកពីរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ច្បាប់ ក្រមសីលធម៌វិជ្ជាជីវៈ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន ជាពិសេស ច្បាប់ស្តីពីរបបសារព័ត៌មាន។ ជនណាក៏ដោយ មិនអាចឆ្លៀតប្រើសិទ្ធិនេះដោយរំលោភ នាំឱ្យប៉ះពាល់ដល់កិត្តិយសអ្នកដទៃ ដល់ទំនៀមទំលាប់ល្អរបស់សង្គម ដល់សណ្តាប់ធ្នាប់សាធារណៈ និងដល់សន្តិសុខជាតិបានឡើយ។ ការប្រើសិទ្ធិសេរីភាពផ្ទាល់ខ្លួនរបស់បុគ្គលម្នាក់ៗ មិនត្រូវឱ្យប៉ះពាល់ដល់សិទ្ធិសេរីភាពអ្នកដទៃឡើយ។

**៥**.- ការរំលោភដ៏ធ្ងន់ធ្ងរផ្នែកវិជ្ជាជីវៈរបស់អ្នកសារព័ត៌មាន ដូចមានចែងក្នុងច្បាប់ស្តីពីរបបសារព័ត៌មាន ជាអំពើល្មើសសារព័ត៌មាន។ សេរីភាពខាងសារព័ត៌មាន មិនផ្តល់អភ័យឯកសិទ្ធិឱ្យអ្នកអនុវត្តសេរីភាពទាំងនេះ រួចផុតពីការទទួលខុសត្រូវចំពោះទង្វើដែលប្រាសចាកពីខ្លឹមសារនៃសេរីភាពទាំងនេះឡើយ។

## ផ្នែកទី ២
## និយាមអប្បបរមានៃការអនុវត្តសកម្មភាពវិជ្ជាជីវៈ

**៦**.- អ្នកអនុវត្តសកម្មភាពក្នុងវិស័យព័ត៌មាននិងសោតទស្សន៍ក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវគោរពច្បាប់ស្តីពីរបបសារព័ត៌មាន និងលិខិតបទដ្ឋានគតិយុត្តទាំងឡាយរបស់ក្រសួងព័ត៌មាន។

**៧**.- អ្នកអនុវត្តសកម្មភាពជាវិជ្ជាជីវៈ ឬអាជីពក្នុងវិស័យព័ត៌មាននិងសោតទស្សន៍ គួរមានគុណវុឌ្ឍិអប្បបរមាមួយចំនួនដូចខាងក្រោម៖

- ជានីតិជន (អាយុ ១៨ ឆ្នាំ ឡើងទៅ) និងមានសមត្ថភាពពេញលេញតាមផ្លូវច្បាប់
- មានកម្រិតវប្បធម៌ យ៉ាងតិចថ្នាក់សញ្ញាបត្រមធ្យមសិក្សាបឋមភូមិ ឬសញ្ញាបត្រដែលមានតម្លៃសមមូល
- ចូលរួមវគ្គបណ្តុះបណ្តាលវិជ្ជាជីវៈសារព័ត៌មានពីគ្រឹះស្ថានអប់រំ សាលាបណ្តុះបណ្តាលវិជ្ជាជីវៈ ឬការបណ្តុះបណ្តាលវិជ្ជាជីវៈផ្សេងៗទៀតរៀបចំដោយក្រសួងព័ត៌មាន សមាគមសារព័ត៌មាន ឬអង្គភាពដែលមានការទទួលស្គាល់ផ្សេងទៀត
- ត្រូវបានចុះឈ្មោះត្រឹមត្រូវ និងត្រូវបានទទួលស្គាល់ជាផ្លូវការដោយក្រសួងព័ត៌មាន។

## ផ្នែកទី ៣
## សុក្រឹតភាពនៃព័ត៌មាន

**៨**.- អ្នកអនុវត្តសកម្មភាពក្នុងវិស័យព័ត៌មាននិងសោតទស្សន៍ ត្រូវឈរលើការពិត និងបង្ហាញព័ត៌មានពិត ចៀសវាងការផ្សាយដំណឹងក្លែងក្លាយ ព័ត៌មានក្លែងបន្លំ ព័ត៌មានបំភ្លៃ ព័ត៌មានភាន់ច្រឡំ ព័ត៌មានមានលក្ខណៈខុសពីការពិត។

**៩**.- អ្នកអនុវត្តសកម្មភាពក្នុងវិស័យព័ត៌មាននិងសោតទស្សន៍ ត្រូវ៖

- ចូលរួមបង្ការទប់ស្កាត់ ប្រឆាំងនឹងការផលិត និងផ្សព្វផ្សាយដំណឹងក្លែងក្លាយ ព័ត៌មានក្លែងបន្លំ ព័ត៌មានបំភ្លៃ ព័ត៌មានភាន់ច្រឡំ
- ផ្សាយតែព័ត៌មានពិត មានប្រភពច្បាស់លាស់ និងបានផ្ទៀងផ្ទាត់ប្រភពត្រឹមត្រូវ
- ផ្ទៀងផ្ទាត់ឡើងវិញ និងកែតម្រូវ ក្នុងករណីបានចុះផ្សាយខុស ឬផ្សាយដោយភាន់ច្រឡំ
- រក្សាការសម្ងាត់នៃប្រភព
- ធានាតុល្យភាពព័ត៌មានប្រកបដោយសច្ចភាព យុត្តិធម៌ និងមិនលម្អៀង។

១០.- អ្នកអនុវត្តសកម្មភាពក្នុងវិស័យព័ត៌មាននិងសោតទស្សន៍ ត្រូវចៀសវាង៖

- ការចុះផ្សាយព័ត៌មាន ដែលគ្មានប្រភពច្បាស់លាស់ ឬធ្វើការចោទប្រកាន់ ដែលមិនមានភស្តុតាងគ្រប់គ្រាន់ និងច្បាស់លាស់
- កាឡៃព័ត៌មានតាមរូបភាពណាមួយ ដែលធ្វើឱ្យប្រាសចាកពីន័យដើម
- បញ្ចេញមតិផ្ទាល់ខ្លួន ឈរលើបុរេនិច្ច័យ
- ច្របល់គ្នារវាងការពិត ដែលជាអង្គហេតុ និង ការយល់ឃើញ ដែលជាទស្សនៈ
- កែប្រែព័ត៌មាន រូបភាព ឬវីដេអូ លុបបំបាត់ចោលផ្នែកព័ត៌មានសំខាន់ៗ ឬបន្លំឯកសារផ្សេងៗ។

## ផ្នែកទី ៤
## គណនេយ្យភាពសង្គម

១១.- អ្នកអនុវត្តសកម្មភាពក្នុងវិស័យព័ត៌មាននិងសោតទស្សន៍ ត្រូវផ្តល់អាទិភាពដល់ព័ត៌មានដែលផ្តល់សារៈប្រយោជន៍ដល់សង្គមជាតិជាទូទៅ និងចៀសវាងការចុះផ្សាយ ដែលបង្កផលប៉ះពាល់ដល់សន្តិភាព សន្តិសុខជាតិសណ្តាប់ធ្នាប់សាធារណៈ សុខដុមនីយកម្មសាសនា ប្រពៃណីទំនៀមទម្លាប់ល្អរបស់សង្គមជាតិ និងសិទ្ធិអ្នកដទៃ។

១២.- អ្នកអនុវត្តសកម្មភាពក្នុងវិស័យព័ត៌មាននិងសោតទស្សន៍ ត្រូវ៖

- ចូលរួមបង្ការ ទប់ស្កាត់ ប្រឆាំងនឹងការផលិតនិងផ្សព្វផ្សាយព័ត៌មានដែលមានចរិតបំពុលសង្គម
- ចូលរួមបំផុស និងបញ្ជ្រាបគោលការណ៍ពហុភាពក្នុងសង្គម ការបើកទូលាយផ្នត់គំនិត និងតម្លៃផ្សេងៗគ្នានៃបុគ្គល និងសង្គម
- ចូលរួមអប់រំសង្គម និងផ្តល់ពុទ្ធិដល់សាធារណជនតាមអត្ថបទសិក្សាស្រាវជ្រាវ ឬរបកគំហើញផ្នែកវិទ្យាសាស្ត្រជាដើម។

១៣.- បុគ្គល ឬអ្នកគ្រប់គ្រងអង្គភាព ដែលអនុវត្តសកម្មភាពក្នុងវិស័យព័ត៌មាននិងសោតទស្សន៍ ត្រូវចៀសវាង៖

- បំផុស ញុះញង់ ឬគាំទ្រព័ត៌មាន ដែលញុះញង់ឱ្យមានការរើសអើង និងការស្អប់ខ្ពើមលើជាតិ សាសន៍ ពណ៌សម្បុរ ឋានៈក្នុងសង្គម ឬនិន្នាការនយោបាយជាដើម
- ញុះញង់ឱ្យមានការប្រព្រឹត្តអំពើល្មើសច្បាប់ ឬអំពើដែលប៉ះពាល់ដល់សន្តិភាព សន្តិសុខជាតិ សណ្តាប់ធ្នាប់សាធារណៈ សុខដុមនីយកម្មសាសនា ប្រពៃណីទំនៀមទម្លាប់ល្អសង្គមជាតិ និងសិទ្ធិអ្នកដទៃ
- ផ្សព្វផ្សាយប៉ះពាល់ដល់អធិបតេយ្យជាតិ បូរណភាពដែនដី ឬទំនាក់ទំនងជាមួយប្រទេសដទៃ
- ចុះផ្សាយរូបភាពកុមារ ដោយមិនមានការអនុញ្ញាតពីអាណាព្យាបាល ឬរូបភាព សំឡេង សន្ទនា ឬវីដេអូ ដែលអាចប៉ះពាល់ដល់កិត្តិយស ឬសេចក្តីថ្លៃថ្នូរបស់បុគ្គល ឬសង្គមជាតិ

- ចុះផ្សាយព័ត៌មាន ដែលប៉ះពាល់ដល់វប្បធម៌ ប្រពៃណី និងទំនៀមទម្លាប់ល្អរបស់ជាតិ ជាអាទិ៍ រូបភាព ឬវីដេអូ ឬប្រលោមលោកអាសអាភាស ជាដើម
- ចុះផ្សាយព័ត៌មាន ដែលប៉ះពាល់សណ្ដាប់ធ្នាប់សាធារណៈ ជាអាទិ៍ រូប/ វីដេអូសកម្មភាព អំពើហិង្សា គ្រោះថ្នាក់ចរាចរណ៍ ជាដើម ដែលអាចបង្កជាភាពតក់ស្លុត ឬបញ្ហាសតិអារម្មណ៍ដល់សាធារណជន
- ឆ្លៀតឱកាស កេងចំណេញលើភាពទន់ខ្សោយ ភាពងាយរងគ្រោះ អសមត្ថភាពផ្លូវចិត្តឬរាងកាយរបស់បុគ្គលណាម្នាក់ ឬក្រុមណាមួយ ដើម្បីផ្សព្វផ្សាយ
- ប្រើពាក្យរិះគន់ ឬបន្តុះបង្អាប់ប៉ះពាល់ដល់ជនមានពិការភាព តម្លៃស្ត្រីនិងកុមារ អ្នកជំងឺផ្លូវកាយនិងផ្លូវចិត្តជាដើម។

## ផ្នែកទី ៥
## ឯករាជភាព និងអព្យាក្រឹត្យភាពរបស់អ្នកសារព័ត៌មាន

**១៤.-** អ្នកអនុវត្តសកម្មភាពក្នុងវិស័យព័ត៌មាននិងសោតទស្សន៍ ត្រូវមាន និងរក្សាឱ្យបាននូវឯករាជភាព អព្យាក្រឹត្យភាព និងចៀសវាងឱ្យខានតែបាននូវការផ្សាយព័ត៌មាន ដែលខ្លួនមានទំនាស់ផលប្រយោជន៍។

**១៥.-** អ្នកអនុវត្តសកម្មភាពក្នុងវិស័យព័ត៌មាននិងសោតទស្សន៍ ត្រូវចៀសវាងៈ

១- ការមានទំនាស់ផលប្រយោជន៍ នៅក្នុងព័ត៌មានដែលខ្លួនចុះផ្សាយ

២- ផ្សាយព័ត៌មាន ដោយលម្អៀងទៅរកភាគី ឬបុគ្គល ឬក្រុមបក្សណាមួយ ដោយឈរលើនិន្នាការ ឬអារម្មណ៍ផ្ទាល់ខ្លួន

៣- យកព័ត៌មានលាយឡំគ្នាជាមួយមតិយោបល់ផ្ទាល់ខ្លួនមកផ្សាយជាដំណឹង

៤- លាយឡំគ្នារវាងដំណឹង ជាមួយការផ្សាយពាណិជ្ជកម្ម។

## ផ្នែកទី ៦
## អនុលោមភាព

**១៦.-** អ្នកអនុវត្តសកម្មភាពក្នុងវិស័យព័ត៌មាននិងសោតទស្សន៍ ត្រូវប្រកាន់ខ្ជាប់ការគោរពរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ច្បាប់ ឬលិខិតបទដ្ឋានគតិយុត្តជាតិនិងអន្តរជាតិជាធរមាន រួមទាំងធម្មនុញ្ញនេះផងដែរ។

**១៧.-** អ្នកអនុវត្តសកម្មភាពក្នុងវិស័យព័ត៌មាននិងសោតទស្សន៍ ត្រូវៈ

- ស្វែងយល់ច្បាស់ពីច្បាប់ និងព្រំដែននៃសេរីភាពរបស់ខ្លួន
- គោរពច្បាប់ និងបទប្បញ្ញត្តិនានាឱ្យបានពេញលេញ
- គោរពសិទ្ធិកម្មសិទ្ធិបញ្ញា សិទ្ធិសេរីភាពបុគ្គល ជាអាទិ៍សេចក្ដីថ្លៃថ្នូរ កិត្តិយសបុគ្គល
- ប្រើប្រាស់ពាក្យពេចន៍ឱ្យបានសុក្រឹតនិងត្រឹមត្រូវតាមវាយ្យករណ៍ ទៅតាមកាលៈទេសៈនិងស្ថានភាព។

**១៨**.- អ្នកអនុវត្តសកម្មភាពក្នុងវិស័យព័ត៌មាននិងសោតទស្សន៍ មិនត្រូវ៖

- ប្រព្រឹត្តហួសព្រំដែននៃសេរីភាពខាងសារព័ត៌មាន
- បរិហារកេរ្តិ៍ បង្កាច់បង្ខូចកិត្តិយសបុគ្គល ជេរប្រមាថ
- ជំរិតទារប្រាក់ (កំហែងទារ) ឬលាភសក្ការៈ ជាថ្នូរនឹងការផ្សាយ ឬមិនផ្សាយព័ត៌មាន
- ផ្តល់សំណូក ឬទទួលសំណូកណាមួយក្នុងសកម្មភាពព័ត៌មាន
- បំពានកម្មសិទ្ធិបញ្ញា សិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល
- ចម្លង កែសម្រួល ឬលួចស្នាដៃអ្នកដទៃមកចុះផ្សាយ ដោយគ្មានការអនុញ្ញាតតាមលក្ខខណ្ឌច្បាប់
- លួងលោមអនីតិជនឱ្យផ្តល់សម្ភាសន៍ ឬដោយមិនស្នើសុំការអនុញ្ញាតពីអាណាព្យាបាល។

## ផ្នែកទី ៧
## ការចូលរួមលើកស្ទួយកិត្យានុភាពវិជ្ជាជីវៈ

**១៩**.- អ្នកអនុវត្តសកម្មភាពក្នុងវិស័យព័ត៌មាននិងសោតទស្សន៍ ត្រូវតម្កល់ឧត្តមប្រយោជន៍នៃវិជ្ជាជីវៈជាស្នូលក្នុងការប្រកបការងារ និងមានកាតព្វកិច្ចចូលរួមលើកស្ទួយគុណតម្លៃវិជ្ជាជីវៈ ដើម្បីទទួលបានទំនុកចិត្តក្នុងសង្គម។

**២០**.- អ្នកអនុវត្តសកម្មភាពក្នុងវិស័យព័ត៌មាននិងសោតទស្សន៍ ត្រូវចៀសវាងទង្វើទាំងឡាយណាដែលនាំឱ្យបង្កភាពអាម៉ាស់និងផលវិបាកធ្វើឱ្យតម្លៃវិជ្ជាជីវៈធ្លាក់ចុះ ដែលប៉ះពាល់ដល់ការលើកកម្ពស់ឧត្តមភាពនិងសេចក្តីថ្លៃថ្នូររបស់អ្នកប្រកបការងារដទៃទៀតក្នុងវិស័យព័ត៌មាននេះ។

**២១**.- ជានិច្ចកាល អ្នកអនុវត្តសកម្មភាពក្នុងវិស័យព័ត៌មាននិងសោតទស្សន៍ ត្រូវរក្សាជំហរឯករាជ្យ មិនលម្អៀង និងភាពស្មោះត្រង់ ត្រូវតម្កល់ផលប្រយោជន៍ប្រជាជននិងសង្គមជាតិជាធំ ហើយមិនត្រូវមានទំនាក់ទំនងផលប្រយោជន៍ជាមួយ ឬស្ថិតក្រោមឥទ្ធិពលនៃ ប្រភពព័ត៌មាន ម្ចាស់ជំនួយ ប្រធានគម្រោង ពាក់ព័ន្ធនឹងប្រធានបទ និងការបំពេញតួនាទីរបស់ខ្លួនឡើយ។

**២២**.- អ្នកអនុវត្តសកម្មភាពក្នុងវិស័យព័ត៌មាននិងសោតទស្សន៍ ត្រូវ៖

- ពង្រឹង និងអភិវឌ្ឍសមត្ថភាពជាប្រចាំ
- ជាភ្នាក់ងារសំខាន់ក្នុងការការពារ និងរក្សាប្រពៃណី ទំនៀមទម្លាប់ អត្តសញ្ញាណ និងវប្បធម៌ជាតិ
- គោរពឱ្យបានត្រឹមត្រូវតាមក្បួនវេយ្យាករណ៍ខ្មែរនិងបរទេស ក្នុងការសរសេរអត្ថបទ និងផលិតមាតិកា
- ចូលរួមពង្រឹងទំនុកចិត្តលើវិជ្ជាជីវៈសារព័ត៌មាន ដោយអនុវត្តបានត្រឹមត្រូវ ពេញលេញតាមធម្មនុញ្ញនេះ និងច្បាប់ជាធរមាន
- ផ្តល់កិច្ចសហការ និងសាមគ្គីភាព ជាមួយអ្នកអនុវត្តសកម្មភាពផ្នែកព័ត៌មានផ្សេងទៀត។

២៣.- អ្នកអនុវត្តសកម្មភាពក្នុងវិស័យព័ត៌មាននិងសោតទស្សន៍ មិនត្រូវ៖

- ប៉ះពាល់ជាអវិជ្ជមានដល់អង្គព្រះមហាក្សត្រ និមិត្តរូបរបស់ជាតិ និងវាយប្រហារ ឬជាន់ឈ្លីស្ថាប័នសាធារណៈជាដើម
- ប្រើពាក្យហិង្សា ជេរប្រមាថ ប៉ះពាល់ដល់សេចក្តីថ្លៃថ្នូរ តម្លៃសង្គម និងធ្វើឱ្យអាប់ឱនដល់តម្លៃវិជ្ជាជីវៈ
- ប្រើពាក្យមិនសមរម្យ ប៉ះពាល់សេចក្តីថ្លៃថ្នូរ វប្បធម៌ជាតិ វិធានអក្សរសាស្ត្រជាតិ
- អនុវត្តបំពានក្រមសីលធម៌វិជ្ជាជីវៈ ដែលធ្វើឱ្យជះឥទ្ធិពលអវិជ្ជមាន ដល់អ្នកប្រកបអាជីពដូចគ្នា ឬធ្វើឱ្យបែកបាក់សាមគ្គីភាពរបស់អ្នកសារព័ត៌មាន
- ទិញ-លក់ព័ត៌មាន ឬលុបចោលព័ត៌មានជាថ្នូរនឹងប្រាក់ ឬអត្ថប្រយោជន៍ផ្សេងទៀត
- ធ្វើជាភ្នាក់ងារចែកចាយដំណឹងក្លែងក្លាយ ព័ត៌មានក្លែងបន្លំ ព័ត៌មានបំភ្លៃ ព័ត៌មានភាន់ច្រឡំ ទាំងក្នុង ឬក្រៅប្រទេស។

## ជំពូកទី ៣
## សិទ្ធិ ករណីយកិច្ច និងការគាំពារ

**២៤.-** ដើម្បីបំពេញតួនាទីរបស់ខ្លួន អ្នកសារព័ត៌មាននិងអង្គភាពសារព័ត៌មានដែលបានចុះបញ្ជីនៅក្រសួងព័ត៌មាន អាចទទួលការគាំពារផ្នែកសុខភាព សង្គម និងខាងផ្លូវច្បាប់ ព្រមទាំងអត្ថប្រយោជន៍ផ្សេងទៀត ដែលបានដាក់ចេញជាផែនការនិងគោលការណ៍អនុគ្រោះសម្រេចដោយរាជរដ្ឋាភិបាលកម្ពុជា ដោយមិនប្រកាន់ជាតិសាសន៍ពណ៌សម្បុរ ឬនិន្នាការនយោបាយអ្វីឡើយ។

**២៥.-** អ្នកសារព័ត៌មាន និងអង្គភាពសារព័ត៌មានដែលបានចុះបញ្ជីនៅក្រសួងព័ត៌មានត្រូវបានផ្តល់បណ្ណសម្គាល់អ្នកសារព័ត៌មាន ទទួលបានការគាំពារនិងមានសិទ្ធិពេញលេញក្នុងការបំពេញការងារ ចុះយកព័ត៌មាននៅទូទាំងប្រទេសកម្ពុជា ដើម្បីផ្សព្វផ្សាយ ឬរាយការណ៍ព័ត៌មានដោយសេរី និងងាយស្រួល។

**២៦.-** អ្នកសារព័ត៌មាន និងអង្គភាពសារព័ត៌មានមានសិទ្ធិ និងករណីយកិច្ចដូចខាងក្រោម៖

១) មានសិទ្ធិចុះយកព័ត៌មាន ស្វែងរកប្រភពព័ត៌មាននានា ដើម្បីផលិតនិងផ្សព្វផ្សាយព័ត៌មានគ្រប់ទម្រង់ដោយសេរី និងគ្រប់ពេលវេលាប្រកបដោយសុវត្ថិភាព សម្រាប់ជាប្រយោជន៍ដល់ការរស់នៅប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋ និងការអភិវឌ្ឍសង្គមជាតិ។

២) មានសិទ្ធិមិនចុះផ្សាយព័ត៌មានដែលខុសនឹងវិជ្ជាជីវៈ មនសិការ និងឆន្ទៈរបស់ខ្លួន។

៣) មានសិទ្ធិសេរីភាពពេញលេញក្នុងការផ្សព្វផ្សាយព័ត៌មានពិត មានប្រភពច្បាស់លាស់ ដោយមិនបំពានសិទ្ធិបុគ្គល មិនបង្កការបង្ខូចកេរ្តិ៍ឈ្មោះ សេចក្តីថ្លៃថ្នូររបស់អ្នកដទៃ។

៤) មានសិទ្ធិទទួលអត្ថប្រយោជន៍នានាក្នុងក្របខណ្ឌនៃការអនុវត្តគោលការណ៍ និងវិធានការគាំពារ របស់រាជរដ្ឋាភិបាល ឬឯកជន ក៏ដូចជាការបំពាក់បំប៉នជំនាញ និងការផ្តល់ការគាំទ្រផ្នែកស្មារតីនិងសម្ភារៈ ក្នុងការអនុវត្តតួនាទីនិងភារកិច្ចរបស់ខ្លួន។

៥) មានកាតព្វកិច្ចគោរពសិទ្ធិបុគ្គល និងគោលការណ៍ច្បាប់ជាធរមាន។ មិនត្រូវផ្សព្វផ្សាយព័ត៌មានដែលបង្កមហន្តរាយដល់សណ្តាប់ធ្នាប់សាធារណៈ ប៉ះពាល់ដល់ស្ថិរភាពក្នុងសង្គម និងសន្តិសុខជាតិ។

៦) មានកាតព្វកិច្ចប្រកាន់ជំហរស្មោះត្រង់ ភាពសុចរិតត្រឹមត្រូវជានិច្ច មិនលម្អៀង ដោយរក្សាតុល្យភាពព័ត៌មាន និងត្រូវផ្តល់ឱកាសដល់គ្រប់ភាគីដែលពាក់ព័ន្ធក្នុងសាច់រឿង។

៧) ត្រូវបែងចែកឱ្យច្បាស់រវាងការផ្តល់ព័ត៌មាន និងការបញ្ចេញមតិផ្ទាល់ខ្លួន ព្រមទាំងជានារាល់ការបញ្ចេញមតិ ឬការរិះគន់ ត្រូវធ្វើឡើងដោយភាពថ្លៃថ្នូរ និងគោរពសិទ្ធិអ្នកដទៃ។

៨) មានកាតព្វកិច្ចរាយការណ៍ព័ត៌មានដោយមានប្រភពច្បាស់លាស់ ត្រូវផ្ទៀងផ្ទាត់ព័ត៌មាន និងចូលរួមប្រឆាំងដំណឹងក្លែងក្លាយ ព័ត៌មានក្លែងបន្លំ ព័ត៌មានបំភ្លៃ និងព័ត៌មានភាន់ច្រឡំ។

៩) ត្រូវលើកកម្ពស់ការគោរពប្រពៃណី ទំនៀមទម្លាប់ និងកេរដំណែលវប្បធម៌ដូនតាខ្មែរ ព្រមទាំងចូលរួមថែរក្សានិងការពារអត្តសញ្ញាណ និងវប្បធម៌ជាតិ។

## ជំពូកទី ៤
## ការទទួលខុសត្រូវ

**២៧.**- ក្នុងក្របខណ្ឌនៃការងារប្រចាំថ្ងៃរបស់ខ្លួន អ្នកអនុវត្តសកម្មភាពក្នុងវិស័យព័ត៌មាននិងសោតទស្សន៍ ត្រូវប្រកាន់ខ្ជាប់នូវការប្រតិបត្តិកាតព្វកិច្ចនិងការទទួលខុសត្រូវដូចខាងក្រោម៖

*១. ទំនួលខុសត្រូវសង្គម៖* បេសកកម្មក្នុងការផ្តល់ព័ត៌មានផ្សារភ្ជាប់ជាមួយសិទ្ធិ កាតព្វកិច្ច និងការទទួលខុសត្រូវសង្គម។ ការផ្សាយព័ត៌មានត្រូវជានាការគោរពឯកជនភាព សេចក្តីថ្លៃថ្នូរបុគ្គលក្នុងសង្គម ហើយមិនត្រូវប៉ះពាល់ដល់សិទ្ធិអ្នកដទៃ ឬតម្លៃវិជ្ជាជីវៈ ដើម្បីការពារប្រយោជន៍និងទំនុកចិត្តសង្គមមកលើតួអង្គក្នុងវិស័យព័ត៌មាន និងចូលរួមក្នុងការអភិវឌ្ឍប្រកបដោយបរិយាបន្ន។

*២. ទំនួលខុសត្រូវវិជ្ជាជីវៈ៖* កំហុសវិជ្ជាជីវៈត្រូវស្ថិតក្រោមការអនុវត្តច្បាប់ស្តីពីរបបសារព័ត៌មាន។ ការអនុវត្តសកម្មភាពក្នុងវិស័យព័ត៌មាននិងសោតទស្សន៍ មិនត្រូវស្ថិតក្រោមគំនាប ឬឥទ្ធិពលរបស់ភាគីណាមួយឡើយ លើកលែងតែការតម្រង់ទិសឬភារកិច្ចដែលប្រធានអង្គភាព-ស្ថាប័នផ្តល់ឱ្យសម្រាប់ករណីអ្នកសារព័ត៌មានអាជីពដែលជាការទទួលខុសត្រូវវិជ្ជាជីវៈ។ ទោះជាយ៉ាងណាក៏ដោយ ការតម្រង់ទិសឬភារកិច្ចដែលប្រធានអង្គភាព-ស្ថាប័នផ្តល់ឱ្យនោះ មិនត្រូវមានចរិតផ្ទុយនឹងច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាននៃព្រះរាជាណាចក្រកម្ពុជា ឬប្រាសចាកពីគន្លងនៃធម្មនុញ្ញនេះឡើយ។

*៣. ទំនួលខុសត្រូវវេជ្ជប្បវេណីនិងព្រហ្មទណ្ឌ៖* អ្នកអនុវត្តសកម្មភាពក្នុងវិស័យព័ត៌មាននិងសោតទស្សន៍ត្រូវគោរពច្បាប់ជាធរមាននៃព្រះរាជាណាចក្រកម្ពុជា។ ទង្វើបំពានក្រៅវិជ្ជាជីវៈសារព័ត៌មាន ត្រូវប្រឈមនឹងផលវិបាកផ្នែករដ្ឋប្បវេណីនិងព្រហ្មទណ្ឌ ដូចមានចែងក្នុងច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។ ទង្វើបំពានប្រភេទទាំងនេះមិនស្ថិតក្នុងក្របខណ្ឌនៃសេរីភាពខាងសារព័ត៌មានឡើយ៕